# សេចក្តីប្រកាសនៃការអនុវត្តន៍ដាច់ដោយឡែក

**វិជ្ជាស្ថានភ្នែកប្រចាំ New England**
940 Commonwealth Avenue, Suite 2, Boston, MA 02215
(617) 262-2020 ext. 5192; (617) 236-6323 (fax)
Richard Bean, អ្នកចាត់ការប្រតិបត្តិ
BeanR@neco.edu

សេចក្តីប្រកាសនេះពណ៌នា  នូវបែបបទដែលគេអាចប្រើ អាចបញ្ចេញឲ្យដឹង  និងអាចចូលទៅកាន់ពត៌មាននេះ។  សូមពិនិត្យមើលវាឲ្យបានហ្មត់ចត់ផង។

យើងខ្ញុំគោរព នូវកាតព្វកិច្ចផ្នែកច្បាប់របស់យើង ដើម្បីថែរក្សាពត៌មានសុខភាពនេះ ដែលប្រាប់ពិនភាគលោកអ្នកជាសម្ងាត់។  យើងខ្ញុំមានកាតព្វកិច្ចតាមច្បាប់ ដើម្បីជូនលោកអ្នក នូវសេចក្តីប្រកាសនៃការអនុវត្តន៍ដោយឡែកទាំងឡាយរបស់យើង។  សេចក្តីប្រកាសនេះពណ៌នា នូវបែបបទដែលយើងខ្ញុំថែរក្សាការពារ នូវពត៌មានសុខភាពរបស់លោកអ្នក  និងនូវសិទ្ធិអ្វីខ្លះ ដែលលោកអ្នកមានទៀតផង។

## ការព្យាបាល, ការបង់ប្រាក់, និងដំណើរការណ៍ថែរក្សាសុខភាព

ហេតុផលដ៏ធម្មតាបំផុត  ដែលយើងខ្ញុំប្រើ ឬ បញ្ចេញឲ្យដឹង នូវពត៌មានសុខភាពរបស់លោកអ្នកនោះ  គឺសំរាប់ការព្យាបាល, ការបង់ប្រាក់ ឬសំរាប់ដំណើរការណ៍នៃការថែរក្សាសុខភាពតែប៉ុណ្ណោះ។  ឧទាហរណ៍ទាំងឡាយនៃបែបបទ  ដែលយើងខ្ញុំប្រើឬបញ្ចេញឲ្យដឹងនូវពត៌មាន សំរាប់គោលបំណងព្យាបាល មានដូចតទៅៈ កំណត់ពេលណាត់ជួបមួយសំរាប់អ្នក; ការធ្វើតេស្ត ឬ ការពិនិត្យភ្នែកអ្នក; ចេញសំបុត្រកាត់វ៉ែនតា, ឡិនស៍ស្រោបលើកែវភ្នែក, ឬថ្នាំព្យាបាលភ្នែក និង ធ្វើតាមហ្វាក់ឲ្យគេបំពេញថែម; បង្ហាញប្រាប់អ្នកនូវប្រដាប់ជាជំនួយ; ប្រាប់អ្នកឲ្យទៅរកវេជ្ជបណ្ឌិតផ្សេងទៀត ខាងថែទាំការពារភ្នែក; ឬសុំចម្លងយកពត៌មានសុខភាពរបស់អ្នកពីកន្លែងផ្សេងទៀត ដែលអ្នកបានទៅជួបគេ មុនពេលបានមកជួបយើងខ្ញុំ។  ឧទាហរណ៍ទាំងឡាយមានដូចជា  យើងប្រើឬបញ្ចេញឲ្យដឹង នូវពត៌មានសុខភាពរបស់អ្នក ក្នុងគោលបំណងនៃការបង់ប្រាក់ដូចជាៈ សួរនាំអ្នកអំពីផែនការថែទាំភ្នែកឬថែទាំសុខភាពរបស់អ្នក ឬប្រភពផ្សេងៗទៀតនៃការបង់ប្រាក់; រៀបចំហើយនិងផ្ញើវិក័យប័ត្រទារឲ្យបង់ប្រាក់; និងប្រមូលទារប្រាក់នៅសេសសល់ (ដោយយើងខ្ញុំ ឬ តាមរយៈភ្នាក់ងារទារប្រាក់ ឬ ដោយមេធាវី)។  “ដំណើរការណ៍ថែទាំសុខភាព “ គឺមានទាំងរដ្ឋបាលគ្រប់គ្រង ទាំងការចាត់ចែង  ដែលយើងខ្ញុំមានដើម្បីដំណើរការការិយាល័យរបស់យើង។  ឧទាហរណ៍មានដូចជា  យើងប្រើនិងបញ្ចេញឲ្យដឹង នូវពត៌មានសុខភាពរបស់អ្នក ក្នុងគោលបំណងថែទាំសុខភាពអ្នកៈ រៀបចំវិក័យប័ត្រទារប្រាក់; ការធ្វើឲ្យជាក់ច្បាស់នូវគុណភាពថែទាំ; សេចក្តីសម្រេចផ្ទាល់ខ្លួន; ចំណូលរួមក្នុងផែនការថែទាំ; ការពារញ្ញោទាំងឡាយទាក់ទងច្បាប់; ផែនការធ្វើជំនួញ; និងទុកដាក់ឯកសាររបស់យើងទៀតផង។

យើងខ្ញុំប្រើប្រាស់យកចេញដាក់ចូលចុះឡើង នូវពត៌មានសុខភាពរបស់អ្នក នៅក្នុងការិយាល័យរបស់យើង ដើម្បីគោលបំណងទាំងនេះ  ដោយមិនចាំបាច់មានការអនុញ្ញាតិដ៏ពិសេសអ្វីទេ។  ប្រសិនបើលោកអ្នកចង់បញ្ចេញឲ្យដឹង នូវពត៌មានសុខភាពរបស់អ្នកទាំងនេះ ក្រៅពីការិយាល័យរបស់យើង  ជាធម្មតា យើងនឹងមិនសួរនាំលោកអ្នក រកការអនុញ្ញាតិជាលាយល័ក្ខអក្សរដ៏ពិសេសអ្វីទេ។

## ការប្រើប្រាស់និងការបញ្ចេញឲ្យដឹង ដើម្បីហេតុផលផ្សេងៗ ដោយមិនមានការអនុញ្ញាតិ

ក្នុងស្ថានការណ៍ខ្លះ  ច្បាប់អនុញ្ញាតឬតម្រូវឲ្យយើង ប្រើប្រាស់និងបញ្ចេញឲ្យដឹង នូវពត៌មានសុខភាពរបស់អ្នក ដោយមិនមានការអនុញ្ញាតិអំពីលោកអ្នកទេ។  គ្មានស្ថានការណ៍ទាំងអស់នេះនឹងអនុវត្តមកលើយើងខ្ញុំទេ; ស្ថានការណ៍ខ្លះប្រហែលមិនដែលកើតមានឡើង នៅការិយាល័យរបស់យើងខ្ញុំទាល់តែសោះ។  ការប្រើប្រាស់និងការបញ្ចេញឲ្យដឹងបែបនេះគឺៈ

- កាលណាច្បាប់រដ្ឋនិងសហព័ន្ធចែងថា  ពត៌មានសុខភាពខ្លះៗ តម្រូវឲ្យរាយការណ៍ ដើម្បីគោលបំណងដ៏ជាក់លាក់ណាមួយ;
- ក្នុងគោលបំណងទាំងឡាយនៃសុខភាពសាធារណៈ  ដូចជាធ្វើរបាយការណ៍ពីជម្ងឺឆ្លង, ធ្វើការតាមដាន ឬ ការឃ្លាំមើល; និងសេចក្តីប្រកាសទៅកាន់និងចេញពីការិយាល័យគ្រប់គ្រងផ្នែកឱសថនិងម្ហូបអាហារ ចំពោះឱសថនិងបរិក្ខារពេទ្យ។
- ការបញ្ចេញឲ្យសមត្ថកិច្ចរដ្ឋាភិបាលដឹង អំពីអ្នករងគ្រោះដោយអំពើរំលោភដែលត្រូវគេសង្ស័យ, អំពើឃោរឃៅក្នុងគ្រួសារ ឬ ដោយការមិនរវល់អើពើ;
- ការប្រើប្រាស់និងការបញ្ចេញឲ្យដឹង សំរាប់សកម្មភាពនៃការត្រួតមើលលើសុខភាព  ដូចជាចេញឡៃសិនឲ្យវេជ្ជបណ្ឌិត; ដើម្បីធ្វើការផ្ទៀងផ្ទាត់ប្រាក់ថ្លៃឈ្នួលដោយក្រសួង Medicare ឬ Medicaid; ឬសំរាប់ការស៊ើបអង្កេតរកការរំលោភលើច្បាប់ថែទាំសុខភាព ដែលអាចកើតមាន;
- ការបញ្ចេញឲ្យដឹង ដើម្បីរៀបចំសំណុំរឿងរដ្ឋបាលនិងតុលាការ  ដូចជាក្នុងការឆ្លើយតបទៅកាន់ការកោះហៅ ឬដីកាតុលាការ ឬ ទីភ្នាក់ងាររបស់រដ្ឋាភិបាលនានា;
- ការបញ្ចេញឲ្យដឹង ពីគោលបំណងដើម្បីពង្រឹងច្បាប់  ដូចជាផ្តល់ពត៌មានអំពីអ្នកណាមួយ  ដែលត្រូវគេសង្ស័យថាជាអ្នករងគ្រោះនៃឧក្រិដ្ឋកម្មមួយ; ផ្តល់ពត៌មានអំពីឧក្រិដ្ឋកម្មមួយ នៅឯការិយាល័យរបស់យើងខ្ញុំ; ឬដើម្បីរាយការណ៍ពីឧក្រិដ្ឋកម្មមួយ ដែលបានកើតឡើងនៅកន្លែងណាមួយផ្សេងទៀត;
- បញ្ចេញឲ្យអ្នកពិនិត្យជម្ងឺដឹង ដើម្បីសំគាល់ប្រាប់មនុស្សស្លាប់ម្នាក់ ឬដើម្បីកំណត់នូវមូលហេតុនៃការស្លាប់; ឬទៅឲ្យនាយកទីបញ្ចុះនានាដើម្បីជួយក្នុងការបញ្ចុះសព; ឬទៅកាន់អង្គការនានាដែលកាន់កាប់ទុកដាក់អំណោយខាងសរីរាង្គ ឬគោលិកាផ្សេងៗ;
- ការប្រើប្រាស់និងការបញ្ចេញឲ្យដឹង សំរាប់ការស្រាវជ្រាវទាក់ទងនឹងសុខភាព;
- ការប្រើប្រាស់និងការបញ្ចេញឲ្យដឹង សំរាប់មុខងាររដ្ឋាភិបាលផ្នែកឯកទេស, ដូចជាការការពារប្រធានាធិបតី ឬមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់; សំរាប់សកម្មភាពនានាជាសម្ងាត់ស្របច្បាប់របស់ជាតិ; សំរាប់គោលបំណងខាងកងទ័ព; ឬសំរាប់ការវិនិច្ឆ័យវាយតម្លៃនិងពិនិត្យសុខភាពនៃសមាជិកទាំងឡាយនៃសេវាកម្មផ្នែកបរទេស;
- ការបញ្ចេញឲ្យដឹងនៃពត៌មាន សំរាប់ផ្លូវផ្គងលើការកត់សំគាល់;
- ការបញ្ចេញឲ្យដឹងដែលទាក់ទងទៅដល់កម្មវិធិផ្តល់កម្រៃដល់អ្នកបំពេញការងារ;
- ការបញ្ចេញឲ្យដឹង សំរាប់ការស្រាវជ្រាវ, សុខភាពសាធារណៈ, សំរាប់ប្រតិបត្តិការទាំងឡាយនៃការថែទាំសុខភាព;
- ការបញ្ចេញឲ្យដឹងកើតមានដោយចៃដន្យ ដែលមិនអាចចៀសវាងបាន  ដោយសារតែការអនុញ្ញាតិឲ្យប្រើប្រាស់ឬការបញ្ចេញឲ្យដឹង;
- ការបញ្ចេញឲ្យដឹង ដល់ “បរិវារខាងធ្វើជំនួញជាមួយគ្នា “  ដែលបំពេញប្រតិបត្តិការថែទាំសុខភាពដើម្បីយើងខ្ញុំ  និងដែលប្តេជ្ញាដើម្បីគោរពដល់ភាពដាច់ដោយឡែកនៃពត៌មានសុខភាពរបស់យើងខ្ញុំ;

**លុះត្រាតែលោកអ្នកជំទាស់  យើងខ្ញុំនឹងចែកចាយផងដែរ នូវពត៌មានពីការថែទាំសុខភាពរបស់អ្នក ជាមួយគ្រួសារអ្នក ឬមិត្តភ័ក្តិអ្នក ដែលកំពុងជួយអ្នក លើការថែទាំភ្នែករបស់អ្នក។**

## សេចក្តីរំលឹកពេលណាត់ជួប

យើងខ្ញុំប្រហែលជាទូរស័ព្ទ ឬ សរសេរ ដើម្បីរំលឹកលោកអ្នក អំពីការណាត់ជួបតាមពេលវេលាកំណត់ ឬក៏ជាពេលជួបពិនិត្យធម្មតា។ យើងខ្ញុំក៏បហែលជាទូរស័ព្ទ ឬ សរសេរផងដែរ ដើម្បីឲ្យដំណឹងលោកអ្នក អំពីការព្យាបាលឬសេវាកម្មផ្សេងទៀត នៅការិយាល័យយើងខ្ញុំ ដែលអាចជួយលោកអ្នកបាន លុះត្រាតែលោកអ្នកប្រាប់យើងខ្ញុំផ្សេងពីនេះទេវិញ។ យើងខ្ញុំនឹងផ្ញើទៅឲ្យលោកអ្នកតាមប៉ុស្តិនូវសេចក្តីរំលឹកនៃការណាត់ជួបមួយ នៅលើប័ណ្ណមួយ ឬទុកបណ្តាំនៃការរំលឹកនេះឲ្យលោកអ្នកតាមទូរស័ព្ទនៅផ្ទះ ឬតាមអ្នកណាម្នាក់ដែលទទួលទូរស័ព្ទ ប្រសិនបើលោកអ្នកមិននៅផ្ទះទេ។

## ការប្រើប្រាស់និងការបញ្ចេញឲ្យដឹងផ្សេងៗទៀត

យើងខ្ញុំនឹងមិនធ្វើនូវការប្រើប្រាស់ឬការបញ្ចេញឲ្យដឹងអំពីពត៌មានសុខភាពរបស់អ្នកទេ លុះត្រាតែលោកអ្នកស៊ីញ៉េ "ពាក្យឲ្យសិទ្ធិអំណាច" ជាលាយល័ក្ខអក្សរ។ ខ្លឹមសារនៃ "ពាក្យឲ្យសិទ្ធិអំណាច" គឺកំណត់ដោយច្បាប់សហព័ន្ធ។ ជួនកាល យើងខ្ញុំប្រហែលជាអាចផ្តួចផ្តើមនូវសិទ្ធិអំណាចនេះ ប្រសិនបើការប្រើប្រាស់និងការបញ្ចេញឲ្យដឹងនេះជាគំនិតរបស់យើង។ ជួនកាលខ្លះទៀត លោកអ្នកប្រហែលជាអាចផ្តួចផ្តើមនូវសិទ្ធិអំណាចនេះ ប្រសិនបើវាជាគំនិតរបស់លោកអ្នក ដើម្បីឲ្យយើងផ្ញើពត៌មានរបស់លោកអ្នក ទៅឲ្យអ្នកណាម្នាក់ផ្សេងទៀត។ ជាទូទៅ ក្នុងសភាពការណ៍បែបនេះ លោកអ្នកនឹងផ្តល់ឲ្យយើងខ្ញុំ នូវពាក្យឲ្យសិទ្ធិអំណាចដ៏ពេញលេញត្រឹមត្រូវមួយ ឬលោកអ្នកអាចប្រើពាក្យឲ្យសិទ្ធិអំណាចមួយ ដែលចេញពីយើងខ្ញុំក៏បានដែរ។

ប្រសិនបើយើងផ្តួចផ្តើម នូវពាក្យសុំសិទ្ធិអំណាចនេះ និងសុំឲ្យលោកអ្នកស៊ីញ៉េ នូវពាក្យសុំសិទ្ធិអំណាចមួយ លោកអ្នកមិនត្រូវស៊ីញ៉េវាទេ។ ប្រសិនបើលោកអ្នកមិនស៊ីញ៉េ នូវពាក្យឲ្យសិទ្ធិអំណាចនេះទេ នោះយើងខ្ញុំមិនអាចធ្វើការប្រើប្រាស់ឬការបញ្ចេញឲ្យដឹងបានទេ។ ស្រិនបើលោកអ្នកស៊ីញ៉េវា លោកអ្នកអាចដកពាក្យចេញវិញគ្រប់ពេល លុះត្រាតែយើងខ្ញុំបានចាត់ចែងវា ហួសផុតទៅ។ ការដកពាក្យចេញត្រូវតែសរសេរជាលាយល័ក្ខអក្សរ។ ផ្ញើវាមកកាន់អ្នកទាក់ទងប្រចាំការិយាល័យ សំដៅឈ្មោះអ្នកណាម្នាក់ នៅខាងដើមនៃសេចក្តីប្រកាសនេះ។

## សិទ្ធិទាំងឡាយរបស់លោកអ្នកចំពោះពត៌មានសុខភាពរបស់លោកអ្នក

ច្បាប់ផ្តល់ឲ្យលោកអ្នក នូវសិទ្ធិជាច្រើន ចំពោះពត៌មានសុខភាពរបស់លោកអ្នកនេះ។ លោកអ្នកអាចៈ

- សុំយើងឲ្យបន្តឹងយ៉ាងហ្មត់ចត់ នូវការប្រើប្រាស់និងការបញ្ចេញឲ្យដឹងទាំងឡាយ សំរាប់គោលបំណងនៃការព្យាបាល (លើកលែងតែការព្យាបាលជាបន្ទាន់) នៃការបង់ប្រាក់ឈ្នួល ឬដំណើរការណ៍ថែទាំសុខភាព។ យើងខ្ញុំមិនត្រូវយល់ព្រមឲ្យធ្វើរឿងនេះទេ ប៉ុន្តែប្រសិនបើយើងខ្ញុំយល់ព្រមទេវិញ យើងខ្ញុំត្រូវតែបំពេញតាមបំណងរបស់លោកអ្នក។ ដើម្បីសួររកការបន្តឹងដ៏ម៉ាត់ធ្យ័តនេះ ចូរផ្ញើសំនើជាលាយល័ក្ខអក្សរ មកកាន់អ្នកទាក់ទងប្រចាំការនៅការិយាល័យ ដែលមានអាស័យដ្ឋាន លេខហ្វាក់ស៍ ឬ អ៊ីម៉េលដែលមានបង្ហាញឲ្យឃើញនៅខាងដើមនៃសេចក្តីប្រកាសនេះ។
- សុំយើងខ្ញុំឲ្យទាក់ទងជាមួយលោកអ្នក ជាសម្ងាត់ ដូចជាឲ្យទូរស័ព្ទមកលោកអ្នកនៅកន្លែងធ្វើការ ប្រសើរជាជាងនៅផ្ទះ ដោយផ្ញើពត៌មានសុខភាពតាមអ៊ីម៉េលផ្ទាល់ខ្លួន ជាដើម។ យើងខ្ញុំនឹងជួយសម្រួលនូវសំនើទាំងនេះ ប្រសិនបើសម្នើទាំងនោះគឺសមហេតុសមផល និងប្រសិនបើលោកអ្នកបង់ប្រាក់ថ្លៃឈ្នួលបន្ថែមលើសធម្មតា។ ប្រសិនបើលោកអ្នកចង់សុំសួររកទំនាក់ទំនងជាសម្ងាត់ ចូរផ្ញើសម្នើជាលាយល័ក្ខអក្សរ ទៅកាន់អ្នកទាក់ទងប្រចាំការិយាល័យ តាមអាស័យដ្ឋាន លេខហ្វាក់ស៍ ឬ អ៊ីម៉េលដែលមានបង្ហាញឲ្យឃើញនៅខាងដើមនៃសេចក្តីប្រកាសនេះ។
- សុំសួរចង់ឃើញ ឬចង់បានថតចម្លងនៃពត៌មានសុខភាពរបស់លោកអ្នកៈ តាមច្បាប់ មានស្ថានភាពកំណត់ខ្លះៗ ដែលក្នុងនោះយើងខ្ញុំអាចជំទាស់មិនអនុញ្ញាតឲ្យដឹង ឬ ចម្លងបានទេ។ តែភាគច្រើន ទោះបីជាយ៉ាងណាក៏ដោយ លោកអ្នកនឹងអាចមើល ឬ មានការថតចម្លងនៃពត៌មានសុខភាពរបស់លោកអ្នក នៅក្នុងកំឡុងពេល 30 ថ្ងៃ នៃការស្នើសុំដល់យើងខ្ញុំ (ឬ60 ថ្ងៃ ប្រសិនបើពត៌មាននោះដំកល់ទុក នៅក្រៅការិយាល័យយើងខ្ញុំ)។ លោកអ្នកប្រហែលជាបង់ថ្លៃឈ្នួល សំរាប់ការថតចម្លង ជាមុន។ ប្រសិនបើយើងខ្ញុំបដិសេធសម្នើរបស់លោកអ្នកវិញ យើងនឹងធ្វើសេចក្តីពន្យល់ប្រាប់ជាលាយលក្ខអក្សរដល់លោកអ្នក និងសេចក្តីណែនាំអំពីហេតុផលមិនលំអៀងនៃការបដិសេធរបស់យើងខ្ញុំ ប្រសិនបើការចង់ឃើញនោះមានទុកជូនដោយស្របច្បាប់។ តាមច្បាប់ យើងខ្ញុំអាចមានការពន្យាពេលចំនួន 30 ថ្ងៃ ដើម្បីយើងខ្ញុំឲ្យលោកអ្នកបានចូលឬបានទទួលការថតចម្លង ប្រសិនបើយើងខ្ញុំផ្ញើទៅឲ្យលោកអ្នក នូវការពន្យាពេលនៃសេចក្តីប្រកាសជាលាយល័ក្ខអក្សរមួយ។ ប្រសិនបើលោកអ្នកចង់មើល ឬ ចង់បានការថតចម្លងនៃពត៌មានសុខភាពរបស់លោកអ្នក ចូរផ្ញើសម្នើជាលាយល័ក្ខអក្សរមួយ ទៅកាន់អ្នកទាក់ទងប្រចាំការិយាល័យ តាមអាស័យដ្ឋាន ហ្វាក់ស៍ ឬ អ៊ីម៉េលដែលមានបង្ហាញឲ្យឃើញនៅខាងដើមនៃសេចក្តីប្រកាសនោះស្រាប់។
- សុំសួរយើងខ្ញុំ ឲ្យកែថែមថយនូវពត៌មានសុខភាពរបស់លោកអ្នក ប្រសិនបើលោកអ្នកគិតឃើញថា វាមិនត្រឹមត្រូវ ឬ មិនពេញលេញ។ ប្រសិនបើលោកអ្នកយល់ព្រម យើងនឹងកែថែមថយ នូវពត៌មានសុខភាពរបស់លោកអ្នកនេះ ក្នុងកំឡុង 60 ថ្ងៃ ពីពេលដែលលោកអ្នកសុំយើងខ្ញុំ។ យើងខ្ញុំនឹងផ្ញើពត៌មានដែលកែតម្រូវទៅឲ្យអ្នកណា ដែលយើងខ្ញុំដឹងថាបានទទួលពត៌មានខុសនោះ និងអ្នកផ្សេងទៀតដែលលោកអ្នកបញ្ជាក់ប្រាប់យើងខ្ញុំ។ ប្រសិនបើលោកអ្នកមិនយល់ព្រមទេ លោកអ្នកអាចសរសេរសេចក្តីថ្លែងបញ្ជាក់នៃជំហររបស់លោកអ្នក ហើយយើងខ្ញុំនឹងដាក់បញ្ចូលវា ជាមួយនឹងពត៌មានសុខភាពរបស់លោកអ្នក ព្រមជាមួយនឹងសេចក្តីអះអាងជំទាស់ណាមួយ ដែលយើងខ្ញុំប្រហែលជាអាចសរសេរ។ គាលបើសេចក្តីថ្លែងបញ្ជាក់ពីជំហររបស់លោកអ្នកនិង/ឬសេចក្តីជំទាស់របស់យើងខ្ញុំមានបញ្ចូលក្នុងពត៌មានសុខភាពរបស់លោកអ្នក យើងខ្ញុំនឹងផ្ញើវាទៅជាមួយ នៅពេលណាដែលយើងខ្ញុំធ្វើសេចក្តីបញ្ជាក់ប្រាប់ឲ្យដឹងពត៌មានសុខភាពរបស់លោកអ្នក តាមការអនុញ្ញាត។ តាមច្បាប់ យើងខ្ញុំអាចមានការពន្យាពេលចំនួន 30 ថ្ងៃមួយ ដើម្បីរំពឹងគិតនូវសម្នើឲ្យមានកំណែថែមថយមួយ ប្រសិនបើយើងខ្ញុំឲ្យដំណឹងលោកអ្នក អំពីការបន្យាពេលជាលាយល័ក្ខអក្សរ។ ប្រសិនបើលោកអ្នកចង់សុំយើងខ្ញុំ ឲ្យកែថែមថយនូវពត៌មានសុខភាពរបស់លោកអ្នក ចូរផ្ញើនូវសម្នើជាលាយល័ក្ខអក្សរ ព្រមជាមួយហេតុផលរបស់លោកអ្នកលើកំណែថែមថយ ទៅឲ្យអ្នកទាក់ទងប្រចាំការិយាល័យ តាមអាស័យដ្ឋាន ហ្វាក់ស៍ ឬ អ៊ីម៉េលដែលមានបង្ហាញឲ្យឃើញនៅខាងដើមនៃសេចក្តីប្រកាសនេះ។
- ចង់បានតារាងនៃការបញ្ចេញឲ្យដឹងអំពីពត៌មានសុខភាពរបស់លោកអ្នក ដែលយើងខ្ញុំបានធ្វើ ក្នុងរយៈពេលកន្លងមកប្រាំមួយឆ្នាំ (ឬខ្លីជាងនេះបើលោកអ្នកចង់)។ តាមច្បាប់ តារាងនេះនឹងមិនរាប់បញ្ចូលៈ ការបញ្ចេញឲ្យដឹងក្នុងគោលបំណងសំរាប់ព្យាបាល សំរាប់បង់ថ្លៃឈ្នួល ឬសំរាប់ដំណើរការណ៍ថែទាំសុខភាព; ការបញ្ចេញឲ្យដឹងដោយមានការឲ្យសិទ្ធអំណាចរបស់លោកអ្នក; ការបញ្ចេញឲ្យដឹងកើតឡើងដោយចៃដន្យ; ការបញ្ចេញ់ឲ្យដឹងដែលស្នើឡើងដោយច្បាប់; និងការបញ្ចេញឲ្យដឹងមានកំណត់ខ្លះៗផ្សេងទៀតផងដែរ។ លោកអ្នកគឺត្រូវទទួលបាននូវការបញ្ចេញឲ្យដឹងណាមួយរាល់ឆ្នាំ ដោយឥតបង់ប្រាក់។ ប្រសិនបើលោកអ្នកចង់បានតារាងនេះញឹកញយដងច្រើនទៀត លោកអ្នកនឹងត្រូវបង់ប្រាក់ជាមុន។ តាមធម្មតាយើងខ្ញុំនឹងឆ្លើយតបដល់សម្នើរបស់លោកអ្នក ក្នុងកំឡុងពេល 60 ថ្ងៃនៃការបានទទួលសម្នើនោះ ប៉ុន្តែតាមច្បាប់ យើងខ្ញុំអាចមានការពន្យាពេលមួយចំនួន 30 ថ្ងៃ ប្រសិនបើយើងខ្ញុំ

ឲ្យដំណឹងលោកអ្នក ពីការពន្យាពេលនោះជាលាយលក្ខអក្សរ។ ប្រសិនបើលោកអ្នកចង់បានតារាងមួយ ចូរផ្ញើសរម្មីជាលាយលក្ខអក្សរមួយ ទៅកាន់អ្នកទាក់ទងប្រចាំការិយាល័យ តាមអាស័យដ្ឋាន ហ្វាក់ស៍ ឬ អ៊ីម៉េលដែលមានបង្ហាញឲ្យឃើញនៅខាងដើមនៃសេចក្តីប្រកាសនោះស្រាប់។

- ចង់បានក្រដាសចម្លងបន្ថែមនៃសេចក្តីប្រកាសអំពីការអនុវត្តន៍ដាច់ដោយឡែក តាមសម្មើនេះ ទោះបីលោកអ្នកចង់បានតាមរយៈអេឡិចត្រូនិក ឬ ជាក្រដាសសម្រាប់បំពេញមានស្រាប់ក៏ដោយ ប្រសិនបើលោកអ្នកចង់បានក្រដាសចម្លងបន្ថែម ចូរផ្ញើសម្មើជាលាយលក្ខអក្សរមួយ ទៅកាន់អ្នកទាក់ទងប្រចាំការិយាល័យ តាមអាស័យដ្ឋាន ហ្វាក់ស៍ ឬ អ៊ីម៉េលដែលមានបង្ហាញឲ្យឃើញនៅខាងដើមនៃសេចក្តីប្រកាសនោះស្រាប់។

## សេចក្តីប្រកាសនៃការអនុវត្តន៍ដាច់ដោយឡែករបស់យើងខ្ញុំ

តាមច្បាប់ យើងខ្ញុំត្រូវតែប្រកាន់ខ្ជាប់ខ្ជួន នូវអត្ថន័យនៃសេចក្តីប្រកាសអំពីការអនុវត្តន៍ដាច់ដោយឡែកនេះ រហូតដល់ពេលណាយើងខ្ញុំចង់ដូរវាចេញ។ យើងខ្ញុំរក្សាសិទ្ធិ ដើម្បីដូរសេចក្តីប្រកាសនេះ នៅពេលណាក៏បាន ឲ្យតែច្បាប់អនុញ្ញាតឲ្យ។ ប្រសិនបើយើងខ្ញុំដូរសេចក្តីប្រកាសនេះ នោះការអនុវត្តន៍ដាច់ដោយឡែកថ្មីនឹងមានអានុភាពលើពត៌មានសុខភាពរបស់លោកអ្នក ដែលយើងខ្ញុំមានរួចមកហើយផង និងទាំងពត៌មានបែបនេះដែលយើងខ្ញុំប្រហែលនឹងបង្កើតនៅពេលអនាគតទៀតផង។ ប្រសិនបើយើងខ្ញុំដូរសេចក្តីប្រកាសអំពីការអនុវត្តន៍ដាច់ដោយឡែកនេះ យើងខ្ញុំនឹងបិទប្រកាសដំណឹងថ្មី នៅក្នុងការិយាល័យរបស់យើងខ្ញុំ មានពាក្យចម្លងទុកសំរាប់ចែកចាយ នៅក្នុងការិយាល័យយើងខ្ញុំ ហើយនិងបិទប្រកាសវានៅលើវ៉ិបសៃត៍របស់យើងខ្ញុំផងដែរ។

## ការតវ៉ា

ប្រសិនបើលោកអ្នកគិតឃើញថា យើងខ្ញុំមិនបានអនុវត្តដោយត្រឹមត្រូវ នូវការសម្ងាត់នៃពត៌មានសុខភាពរបស់លោកអ្នកទេ លោកអ្នកអាចប្តឹងតវ៉ាមកយើងខ្ញុំគ្រប់ពេល ឬទៅកាន់ក្រសួងសុខាភិបាលជាតិ ផ្នែកការិយាល័យទទួលបន្ទុកសិទ្ធិពលរដ្ឋ។ យើងខ្ញុំនឹងមិនតវ៉ាប្រឆាំងនឹងលោកអ្នកវិញទេ ប្រសិនបើលោកអ្នកធ្វើការតវ៉ាមួយ។ ប្រសិនបើលោកអ្នកចង់តវ៉ាមកកាន់យើងខ្ញុំ ចូរផ្ញើការតវ៉ាជាលាយលក្ខអក្សរមួយ ទៅកាន់អ្នកទាក់ទងប្រចាំការិយាល័យ តាមអាស័យដ្ឋាន ហ្វាក់ស៍ ឬ អ៊ីម៉េលដែលមានបង្ហាញឲ្យឃើញ នៅខាងដើមនៃសេចក្តីប្រកាសនោះស្រាប់។ ប្រសិនបើលោកអ្នកចង់ផ្សេងពីនេះ លោកអ្នកអាចជជែកពិភាក្សា នូវការតវ៉ារបស់លោកអ្នកជួបតទល់គ្នា ឬ តាមទូរស័ព្ទក៏បាន។

## សម្រាប់ពត៌មានបន្ថែម

ប្រសិនបើលោកអ្នកចង់បានពត៌មានបន្ថែម អំពីការអនុវត្តន៍ដាច់ដោយឡែករបស់យើងខ្ញុំនេះ ចូរទូរស័ព្ទ ឬ មកជួបអ្នកទាក់ទងប្រចាំការិយាល័យ តាមអាស័យដ្ឋាន ហ្វាក់ស៍ ឬ អ៊ីម៉េលដែលមានបង្ហាញឲ្យឃើញ នៅខាងដើមនៃសេចក្តីប្រកាសនោះស្រាប់។